ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

**COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)**

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA. P.O. Box 1145,
Tel: (855) 23 884 150 Fax: (855) 23 883 750 E-mail: comfrel@online.com.kh URL: www.comfrel.org



**គណៈកម្មាធិការនាយក**
**BOARD OF DIRECTORS**

លោក **ធុន សារាយ**
**Mr. THUN Saray**
ជាប្រធានគណៈកម្មាធិការនាយក និងជាប្រធានសមាគម **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
ជាអនុប្រធានគណៈកម្មាធិការនាយក និងជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គហិរញ្ញិក និងជានាយក **CCPCR**

លោក **យៀង វណ្ណា**
**Mr. YEANG Vanna**
ប្រធាន **KKKHRA**

លោក **ជីវ យូម៉េង**
**Mr. CHIV You Meng**
ប្រធាន **KYA**

លោកស្រី **ពឹង យក់ហៀប**
**Ms. PEUNG Yok Hiep**
នាយិកា **LAC**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
ប្រធាន **PDP Center**

លោក **ទូច ទុម្ព**
**Mr. TOUCH Tum**
នាយក **VIGILANCE**

លោកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

កញ្ញា **សយ សារា វឌ្ឍនី**
**Ms. SAY Sara Vathany**
នាយិកា **CWCC**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**
**ឥស្សរជន**

លោក **សឺន សែត**
**Mr. SEN Set**
**ឥស្សរជន**


ស.ប្រ.ក.៣/លេខ ១១/០៨ គ.ប.ស.យ/អ.ក

# សេចក្តីថ្លែងការណ៍ និង
# របាយការណ៍សង្កេតបឋមលើកទី ៦
# ស្តីពី
# បរិយាកាសឃោសនាបោះឆ្នោត ឆ្នាំ ២០០៨ ក្នុងសប្តាហ៍ទីពីរ

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៨*

**គណៈកម្មាធិការ ខុមហ្វ្រែល** សំដែងនូវការព្រួយបារម្ភ ចំពោះបរិយាកាសអសន្តិសុខកើនឡើងបន្តបន្ទាប់ក្នុងដំណាក់កាលឃោសនាបោះឆ្នោត ជាពិសេសករណីឃាតកម្មលើ**លោក យឹម សម្បូរណ៍** អ្នកសារព័ត៌មានមនសិការខ្មែរ ដែលមាននិន្នាការគាំទ្រគណបក្សសមរង្ស៊ី និងកូនប្រុស កាលពីយប់ថ្ងៃទី ១១ កក្កដា នៅកណ្តាលទីក្រុងភ្នំពេញ។ ខុមហ្វ្រែល **ថ្កោលទោសភាពកំសាក** នៃអំពើឃាតកម្មនេះ ដែលករណីនេះបាន**ធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍ភ័យខ្លាចរបស់អ្នកបោះឆ្នោត ពិសេសគំរាមកំហែងផ្ទាល់ដល់**អ្នកសារព័ត៌មាន និងសកម្មជនគណបក្សនយោបាយ ។ លោក **ធន សារាយ** ប្រធានគណៈកម្មាធិការនាយករបស់ ខុមហ្វ្រែល អំពាវនាវឱ្យ *"អាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការស៊ើបអង្កេតរកមុខរកជនដៃដល់មកផ្តន្ទាទោសតាមច្បាប់ជាធរមាន ដើម្បីចូលរួមធានាឱ្យមានបរិយាកាសសន្តិសុខប្រសើរឡើងវិញ នៅមុនពេលបោះឆ្នោត"* ។

**ខុមហ្វ្រែល ផ្តល់យោបល់ដល់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)៖**

- *ត្រូវចាត់វិធានការគ្រប់បែបយ៉ាង ទប់ស្កាត់ និងប្រឆាំងរាល់ការគំរាមកំហែង បំភិតបំភ័យ និងរារាំងដល់សកម្មជន និងសកម្មភាពឃោសនារបស់គណបក្សនយោបាយ*
- *ពង្រឹងប្រព័ន្ធផ្សព្វផ្សាយឯកជនដើម្បីឱ្យគោរពបទបញ្ជា នីតិវិធី គោលការណ៍ និងក្រមសីលធម៌*
- *ពង្រឹងបន្ថែមការងារអង្កេត និងការដោះស្រាយបណ្តឹងនានា*
- *លើកទឹកចិត្តឱ្យអ្នកសង្កេតការណ៍របស់អង្គការ សមាគមមិនមែនរដ្ឋាភិបាលជួយអ្នកបោះឆ្នោត ដែលជួបឧបសគ្គរកឈ្មោះមិនឃើញ នៅថ្ងៃបោះឆ្នោត ។*

ក្នុងកំឡុងពេលឃោសនាបោះឆ្នោតសប្តាហ៍ទីពីរនេះដែរ ខុមហ្វ្រែល ក៏បានសង្កេតឃើញ ករណីឃាតកម្ម ការគំរាមកំហែង ការរំលោភច្បាប់ បទបញ្ជា នីតិវិធីបោះឆ្នោត និងភាពមិនប្រក្រតីមួយចំនួនបានកើតឡើងផងដែរ ករណីទាំងនោះមានដូចជា៖

## ១- បរិយាកាសសន្តិសុខ ករណីឃាតកម្ម ការគំរាមកំហែង បំភិតបំភ័យ

តាមរបាយការណ៍របស់បណ្តាញ ខុមហ្វ្រែល មានករណីឃាតកម្ម ការគំរាមកំហែង បំភិតបំភ័យកើនឡើងនៅក្នុងសប្តាហ៍ទីពីរនេះ។ មានឃាតកម្មចំនួន **៣** ករណីបានកើតឡើង ដែលបានធ្វើឱ្យសកម្មជន អ្នកគាំទ្រគណបក្សនយោបាយ អ្នកសារព័ត៌មានសរុបចំនួន **៣** នាក់ បានស្លាប់។ ករណីទាំងនោះ មានដូចជា:

- ករណីឃាតកម្មទៅលើលោក **សួត សុង** សកម្មជនគណបក្សប្រជាជនកម្ពុជានៅភូមិអង្គតាឯក ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ នៅថ្ងៃទី ០១ កក្កដា។ ចំពោះករណីនេះ គណបក្សសិទ្ធិមនុស្ស ក៏បានអះអាងថាជាសមាជិករបស់ខ្លួនផងដែរ។
- ករណីឃាតកម្មទៅលើលោក **លន ចក់** សកម្មជនគណបក្សប្រជាជនកម្ពុជានៅភូមិព្រៃគ្រី ឃុំព្រៃគ្រី ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នៅថ្ងៃទី ០៦ កក្កដា។

  ករណីទាំងពីរខាងលើនេះ ត្រូវបានអាជ្ញាធរមូលដ្ឋាន និងអង្គការសិទ្ធិមនុស្ស អះអាងជាជំហានដំបូងថា មិនជាប់ពាក់ព័ន្ធនឹងរឿងនយោបាយទេ វាជាប់ពាក់ព័ន្ធនឹងករណីគំនុំ និងបញ្ហាជម្លោះដីធ្លី។
- ករណីឃាតកម្មលើ **លោក ឃឹម សម្បូរណ៍** ឈ្មោះពិត **ឃឹម ខាត់សារិទ្ធ** អាយុ ៤៧ ឆ្នាំ អ្នកសារព័ត៌មានមនសិការខ្មែរ ដែលមាននិន្នាការគាំទ្រគណបក្សសមរង្ស៊ី និងកូនប្រុសឈ្មោះ ខាត់សារិទ្ធ ជាតា អាយុ ២១ ឆ្នាំ កាលពីយប់ថ្ងៃទី ១១ កក្កដា នៅកណ្តាលទីក្រុងភ្នំពេញ ដោយជនប្រដាប់អាវុធពីរនាក់បាញ់ប្រហារនៅពេលលោកចេញពីហាត់ប្រាណនៅពហុកីឡាដ្ឋានជាតិអូឡាំពិច។ គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា បានធ្វើការសន្និដ្ឋានជាជំហានដំបូងថា ករណីឃាតកម្មនេះ អាចបណ្តាលមកសកម្មភាពបំពេញវិជ្ជាជីវៈរបស់គាត់ ព្រោះអត្ថបទដែលគាត់បានសរសេរភាគច្រើនផ្តោតជា ចម្បងទៅលើបញ្ហាទំនាស់នយោបាយ ភាពមិនប្រក្រតីនៃដំណើរការបោះឆ្នោត ការកាប់បំផ្លាញព្រៃឈើ បទល្មើសនេសាទ ការទន្ទ្រានដីធ្លី ដែលជាប់ពាក់ព័ន្ធជាមួយនឹងមន្ត្រីមានអំណាចធំៗ។

ក្រៅពីករណីឃាតកម្មខាងលើ ក៏មានការគំរាមកំហែង បំភិតបំភ័យ ដល់សកម្មជនគណបក្សនយោបាយ ដូចជា:

- មានការអះអាងពីការប៉ុនប៉ងធ្វើឃាតលើរូបលោក អ៊ុំ សារ៉ា អ្នកធ្វើអត្ថាធិប្បាយឱ្យកម្មវិធីពន្លឺភ្លើងទៀនរបស់ គណបក្សសមរង្ស៊ី នៅទីក្រុងភ្នំពេញ នាថ្ងៃទី ៦ កក្កដា។
- ករណីគំរាមកំហែងដល់អាយុជីវិត ឬធ្វើទុក្ខទោសដល់រូបរាងកាយមានចំនួន **១៦** ករណី ដែលកើតមាននៅខេត្តសៀមរាប បាត់ដំបង កំពង់ចាម កំពង់ធំ កំពង់ស្ពឺ កំពត ស្វាយរៀង ព្រៃវែង និងឧត្តរមានជ័យ...។ ជនរងគ្រោះភាគច្រើនមកពីគណបក្សសមរង្ស៊ី គណបក្សនរោត្តម រណឬទ្ធិ គណបក្សសិទ្ធិមនុស្ស ហើយអ្នកប្រព្រឹត្តភាគច្រើនជាមន្ត្រីអាជ្ញាធរមូលដ្ឋាន និងអ្នកដែលមាននិន្នាការគាំទ្រគណបក្សប្រជាជនកម្ពុជា។
- មានការកើនឡើងនូវករណីចោរលួច ឆក់ ប្លន់សម្លាប់ បើធៀបនឹងខែមុនៗ ដែលបង្កឱ្យប្រជាពលរដ្ឋមានការភ័យខ្លាចបន្ថែមទៅលើបញ្ហាសន្តិសុខក្នុងពេលបោះឆ្នោត។ ករណីទាំងនោះច្រើនកើតមាននៅរាជធានីភ្នំពេញ ខេត្តកំពង់ចាម បាត់ដំបង សៀមរាប ព្រៃវែង ស្វាយរៀង កណ្តាល តាកែវ...ដែលក្នុងខែមិថុនា មានករណីចោរលួច ឆក់ ប្លន់សម្លាប់ចំនួន **៦៤** ករណី និងគិតត្រឹមពាក់កណ្តាលខែ កក្កដា មានចំនួន **៤១** ករណី។

## ២- ភាពមិនប្រក្រតីនានា

មានភាពមិនប្រក្រតីមួយចំនួនបានកើតឡើងនៅក្នុងកំឡុងពេលឃោសនាបោះឆ្នោត។ ករណីទាំងនោះមានដូចជា:

- ការចែកអំណោយក្នុងន័យទិញសន្លឹកឆ្នោត ចំនួន ៦ ករណី សៀមរាប ២ ករណី កំពង់ឆ្នាំង ២ ករណី ព្រៃវែង ១ ករណី និង ពោធិ៍សាត់ ១ ករណី។
- ការហែកខិតប័ណ្ណ និងការទម្លាក់ស្លាកគណបក្សនយោបាយ មាន ច្រើនករណី ដែលភាគច្រើនកើតមាននៅខេត្តបាត់ដំបង បន្ទាយមានជ័យ ភ្នំពេញ កំពត កំពង់ចាម កណ្ដាល ព្រៃវែង និងស្ទឹងត្រែង។ ប្រជាពលរដ្ឋសាមញ្ញ មានការអត់ឱនច្រើនជាងអាជ្ញាធរភូមិ ឃុំ ដែលផ្ដល់ឱ្យគណបក្សនយោបាយនានា បានបិទខិតប័ណ្ណ និងផ្ទាំងរូបភាពឃោសនានានា បើទោះបីគ្មានការសុំអនុញ្ញាតជាមុនពីពួកគេ (ម្ចាស់ផ្ទះផ្ទាល់)។ គណបក្សនយោបាយដែលបានបិទខិតប័ណ្ណ ផ្ទាំងរូបភាព និងបដាច្រើនជាងគេ គឺគណបក្សប្រជាជនកម្ពុជា បន្ទាប់មកគឺគណបក្សសមរង្ស៊ី សិទ្ធិមនុស្ស នរោត្តមរណឫទ្ធិ និងហ៊្វុនស៊ិនប៉ិច។
- ករណីដកហូតអត្តសញ្ញាណប័ណ្ណពីសមាជិកគណបក្សហ៊្វុនស៊ិនប៉ិច ដោយអាជ្ញាធរ ២ ករណី នៅខេត្តបន្ទាយមានជ័យ។
- ការបង្កជម្លោះ និងរារាំងសកម្មភាពឃោសនារបស់គណបក្សនយោបាយ មានចំនួន ៤ ករណី។ ជាក់ស្ដែងដូចជាករណីរារាំងសកម្មភាពឃោសនារបស់គណបក្សសិទ្ធិមនុស្ស ពីសំណាក់ក្រុមសន្តិសុខផ្សារអូរឫស្សីជាដើម។
- អាជ្ញាធរ មន្ត្រីរាជការស៊ីវិល និងកម្លាំងប្រដាប់អាវុធមួយចំនួនធំ បន្តចូលរួមឃោសនាឱ្យគណបក្សកាន់អំណាច ដែលស្ទើរតែគ្រប់២៤ខេត្ត/ក្រុង។ **ខុមហ្វ្រែល** សង្កេតឃើញថា មានមន្ត្រីរាជការមួយភាគធំនៅតាមក្រសួង/មន្ទីរនានា មិនបានចូលបំរើការងារនៅក្នុងពេលម៉ោងរដ្ឋបាលបំពេញការងាររបស់ខ្លួន។ មេភូមិ និងអាជ្ញាធរមួយចំនួន ក៏បានទៅប្រឆាំង និងរារាំងសកម្មភាពឃោសនានានា របស់គណបក្សនយោបាយ។

ខុមហ្វ្រែល ក៏បានទទួល និងតាមដានករណីបណ្ដឹងចំនួន ២៦ ក្នុងនោះមានបណ្ដឹងរបស់គណបក្ស សម រង្ស៊ី ចំនួន ១១ បណ្ដឹង ដែលផ្ដោតទៅលើការគំរាមគំហែងសកម្មជនគណបក្សនយោបាយ និងការរំលោភលើបទបញ្ជា និងនីតិវិធីឃោសនាបោះឆ្នោតរបស់មន្ត្រីគណបក្សប្រជាជនកម្ពុជា បណ្ដឹងរបស់គណបក្សប្រជាជនកម្ពុជា ចំនួន ៦ ករណី ដែលភាគច្រើនផ្ដោតលើការនិយាយបរិហាកេរ្តិ៍ប៉ះពាល់ដល់បុគ្គលដែលខុសទៅនឹងនីតិវិធីឃោនាបោះឆ្នោត និងបណ្ដឹងរបស់គណបក្សនរោត្តមរណឫទ្ធិចំនួន ៣ ករណី ដែលផ្ដោតលើការមិនយកចិត្តទុកដាក់របស់អាជ្ញាធរមានសមត្ថកិច្ច ក្នុងការកាពារឱ្យសិទ្ធិស្មើគ្នាក្នុងសកម្មភាពឃោសនា គណបក្សហ៊្វុនស៊ិនប៉ិច ២ បណ្ដឹង នៅបន្ទាយមានជ័យ ពីបទដកហូតអត្តសញ្ញាណប័ណ្ណ និងខិតប័ណ្ណ ព្រមទាំងបណ្ដឹងរបស់គណបក្សសិទ្ធិមនុស្សចំនួន ១ ករណី ដែលផ្ដោតលើការបំផ្លាញទ្រព្យសម្បត្តិរបស់គណបក្ស។ មានករណីពិសេសមួយនៅខេត្តរតនៈគិរី ដែលមន្ត្រីអធិការរងនគរបាលស្រុកបរកែវ ខេត្តរតនៈគិរី កាលពីថ្ងៃទី ២ កក្កដា បានចាប់ខ្លួនក្មេងអាយុ ១៧ ឆ្នាំ និងប្អូន ជំរិតទារប្រាក់ ១៥ ម៉ឺនរៀល ដោយចោទប្រកាន់ពីបទបំផ្លាញស្លាកសញ្ញាគណបក្សប្រជាជនកម្ពុជា។

## ៣- ការដាក់ពាក្យប្ដឹង នីតិវិធីទទួល និងដោះស្រាយបណ្ដឹង

ខុមហ្វ្រែល យល់ឃើញថា **ភ្នាក់ងារគណបក្សនយោបាយហាក់មានការយល់ដឹងប្រសើរជាងការបោះឆ្នោតមុនៗ** ក្នុងការបំពេញពាក្យប្តឹង ដូចជាកម្មវត្ថុបណ្តឹង ការប្រមូលភស្តុតាង សាក្សី ការគោរពពេលវេលា និងមានការសម្រួលក្នុងការទទួលពាក្យបណ្តឹងតាមរយៈសេចក្តីណែនាំរំលឹករបស់ គ.ជ.ប ស្តីពីការពិនិត្យ/ទទួល និងការដោះស្រាយបណ្តឹងនៅ គឃ/សប ក្នុងដំណាក់កាលឃោសនាបោះឆ្នោត ចុះថ្ងៃទី ០៣ កក្កដា ២០០៨។ **ការចោរបដិសេធបណ្តឹង មានចំនួនតិចត្រឹមតែ ១២** ករណីប៉ុណ្ណោះក្នុងចំណោម **១១៦** បណ្តឹង[១] នៅថ្នាក់ឃុំ/សង្កាត់ បើធៀបការបោះឆ្នោតមុនៗ ការបដិសេធបណ្តឹងមានរហូតដល់ ៨០% នៃពាក្យបណ្តឹង។

ដោយមិនសុខចិត្តនឹងលទ្ធផលនៃការផ្សះផ្សារនៅ គឃ/សប ពាក្យបណ្តឹងចំនួន ៥០ បានធ្វើឧទ្ធរណ៍បន្តទៅគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត (គខ/កប)។ ចំណែកឯពាក្យបណ្តឹង ៦ ត្រូវបានដាក់ផ្ទាល់ទៅគខ/កប ដោយប្តឹងពីមន្ត្រីគឃ/សប។ មានបណ្តឹង ចំនួន **២២** បានដាក់ប្តឹងបន្តទៅគ.ជ.ប។ ក្នុងចំណោម ១១៦ បណ្តឹងដែលបានដាក់ ជាលទ្ធផលសះជានឹងគ្នាមានចំនួនតែ **២៩** បណ្តឹង ចំណែកឯការមិនសះជា មានរហូតដល់ ៥២ ករណី។ កម្មវត្ថុនៃបណ្តឹងទាំងនោះមាន:

- ៧ ករណី ទាក់ទងនឹងការទិញសន្លឹកឆ្នោត
- ៩ ករណី ទាក់ទងនឹងការចូលរួមរបស់មន្ត្រីសាធារណៈ រួមទាំងបព្វជិតសាសនា ក្នុងដំណើរការឃោសនា
- ១៩ ករណី ទាក់ទងនឹងការរំខានការប្រព្រឹត្តទៅនៃការឃោសនារបស់គណបក្សនយោបាយ
- ៣១ ករណី ទាក់ទងនឹងការបំផ្លាញសម្ភារៈឃោសនារបស់គណបក្សនយោបាយ
- ១៦ ករណី ទាក់ទងនឹងការរំខាននឹងការគំរាមកំហែង រួមទាំងការប៉ុនប៉ងមនុស្សឃាត
- ២០ ករណី ទាក់ទងនឹងការបរិហាកេរ្តិ៍ ឬ/និងការជេរប្រមាថ
- ១២ ករណី ទាក់ទងនឹងការរំលោភជាទូទៅ លើបទបញ្ជា និងនីតិវិធី
- ១ ករណី ទាក់ទងនឹងការប្រើប្រាស់អាគារសាធារណៈ
- ១ ករណី ហាក់ដូចមិនសមជាកម្មវត្ថុនៃបទល្មើស (ករណីប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលសុំឈ្មោះសមាជិក និងភ្នាក់ងារគណបក្ស)

ការសង្កេតរកឃើញថា ដំណើរការដោះស្រាយបណ្តឹងរបស់អាជ្ញាធររៀបចំការបោះឆ្នោត ជាពិសេស ថ្នាក់ខេត្ត/ក្រុង **ភាគច្រើនបានដំណើរការបើកសវនាការស្របតាមបទបញ្ជា និងនីតិវិធីបោះឆ្នោត** និងមានការដាក់ទោសទណ្ឌអ្នកប្រព្រឹត្តល្មើសមួយចំនួន។ ឧទាហរណ៍មានការសម្រេចរបស់ គខ/កប ក្នុងការ**ដកសិទ្ធិបោះឆ្នោតប្រាំឆ្នាំ** ចំនួន **៣** រូប នៅក្នុងខេត្តកំពង់ចាម **ពិន័យជាប្រាក់ប្រាំលានរៀល** ចំនួន **៤** ករណី ដូចជាករណីជាក់ស្តែងការទិញសន្លឹកឆ្នោតនៅខេត្តពោធិ៍សាត់ និងបញ្ឈប់ពីការងារនូវមន្ត្រី គឃ/សប មួយរូប នៅខេត្តបាត់ដំបងជាដើម។ ទោះបីជាយ៉ាងណាក៏ដោយ ការសម្រេចខ្លះមិនទាន់ស្របច្បាប់ ដូចជាករណីសម្រេចឱ្យមាន "**ការព្រមាន**" ចំពោះករណីចំនួន ៣ នៅខេត្តបាត់ដំបង កំពង់ចាម និងកំពត

[១] យោងតាមប្រកាសលេខ ០៧.១២៦/០៨ គ.ជ.ប.អគ្គ.ពស ចុះថ្ងៃទី ១៤ ខែ កក្កដា ២០០៨។

និងករណីពិន័យជាប្រាក់ ៥ លានរៀលចំពោះអ្នកប្រព្រឹត្តល្មើសចំនួនពីរនាក់នៅខេត្តកំពត ដែល ពុំមានចែងនៅក្នុងមាត្រាណាមួយនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ហើយច្បាប់បានបង្ហាញថា "**ទោសប្បញ្ញត្តិនេះ ត្រូវផ្តន្ទាទោស**" និង"**សាមីជនម្នាក់ៗ ត្រូវមានការទទួលខុសត្រូវចំពោះទណ្ឌកម្មរៀងៗខ្លួន**"។ ការសង្កេតឃើញថា ភាគីដើមបណ្តឹង និង ចុងចម្លើយមួយចំនួន **មិនទាន់ពេញចិត្តជាមួយនឹងដំណោះស្រាយរបស់ គខ/កប នោះទេ** ដោយបានលើកហេតុផលថា ការដោះស្រាយនោះ មិនទាន់បានគោរពពេញលេញទៅតាមច្បាប់ និងទោសប្បញ្ញត្តិនៅឡើយ ហើយចុងចម្លើយក៏បានដាក់ពាក្យប្តឹងបន្តមក គ.ជ.ប ដើម្បីទាមទាររកយុត្តិធម៌ឱ្យបានពេញលេញ។

គួរកត់សម្គាល់ថា មានឥស្សរជននយោបាយល្បីៗមួយចំនួន និងដែលជាបេក្ខជនឈរឈ្មោះបោះឆ្នោត បានទទួលរងនូវការប្តឹង តួយ៉ាងដូចជា ឯកឧត្តម សម រង្ស៊ី ពីបទរំលោភលើក្រមសីលធម៌ បទបញ្ជា និងនីតិវិធីនៃការឃោសនាបោះ-ឆ្នោត នៅខេត្តក្រចេះ កំពង់ចាម ពោធិ៍សាត់ បាត់ដំបង ឯកឧត្តម លី ធុច ពីបទទិញសន្លឹកឆ្នោតនៅខេត្តពោធិ៍សាត់ ឯកឧត្តម សៀង ណាំ ពីបទទិញសន្លឹកឆ្នោតនៅខេត្តសៀមរាប ឯកឧត្តម ព្រុំ សុខា ពីបទទិញសន្លឹកឆ្នោតនៅខេត្តព្រៃវែង។

**៤- ការផ្សាយរបស់ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចក្នុងអំឡុងពេលឃោសនាបោះឆ្នោត**

**៤.១ ការរំលោភក្រមសីលធម៌ និងគោលការណ៍ណែនាំរបស់គណៈកម្មាធិជាតិរៀបចំការបោះឆ្នោត** (គ.ជ.ប)

ប្រព័ន្ធផ្សព្វផ្សាយឯកជន (ទូរទស្សន៍ឯកជនទាំងអស់ និងវិទ្យុមួយចំនួនធំដែលមានលទ្ធភាពគ្របដណ្តប់ស្ទើរគ្រប់ខេត្ត/ក្រុង) យ៉ាងតិចចំនួន ៣០ បន្ត និងកំពុងតែរំលោភយ៉ាងខ្លាំងទៅលើក្រមសីលធម៌អ្នកសារព័ត៌មាន និងគោលការណ៍ណែនាំសម្រាប់ប្រព័ន្ធផ្សព្វផ្សាយរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។ ឧទាហរណ៍ វិទ្យុបាយ័ន FM 95 MHz បាននិងកំពុងផលិតកម្មវិធីប្រចាំថ្ងៃ "នាទីវប្បធម៌ខ្មែរ" ដែលបានចាក់ផ្សាយបន្តដោយស្ថានីយវិទ្យុយ៉ាងតិចចំនួន ៦[២] បាន និងកំពុងតែប្រើប្រាស់ពាក្យពេជន៍អសុរស គ្មានសីលធម៌ ញុះញង់ និងបង្កឱ្យមានការរើសអើងដល់គណបក្សផ្សេងៗទៀត ដូចជាពាក្យ "ពួកអាអគតិ ពួកអសិរពិស ពួកបំផ្លាញជាតិ..." ជាពិសេសដល់គណបក្សសមរង្ស៊ី គណបក្សសិទ្ធិមនុស្ស គណបក្សនរោត្តមរណឫទ្ធិ។ ជាមួយគ្នានេះ ប្រព័ន្ធផ្សព្វផ្សាយទាំងទូរទស្សន៍ និងវិទ្យុឯកជនទាំងនេះក៏បានបន្តការផលិតកម្មវិធីគាំទ្រដល់គណបក្សប្រជាជនកម្ពុជា និង/ប្រឆាំងគណបក្សផ្សេងៗទៀត។ ប្រព័ន្ធផ្សព្វផ្សាយទាំងនេះមិនគោរពគោលការណ៍ការបង្កើតកម្មវិធីស្មើភាព ឬសមធម៌ និងការជួលម៉ោងជាចំហររបស់ គ.ជ.ប នោះទេ។

ពាក្យពេជន៍រំលោភក្រមសីលធម៌ក៏ត្រូវបានឮនៅក្នុងប្រព័ន្ធផ្សព្វផ្សាយដែលបើកចំហរជួលម៉ោងផ្សាយដល់ គណ-បក្សនយោបាយនានា[៣]។ ឧទាហរណ៍ វិទ្យុមហានគរ FM 93.5 MHz បានចាក់ផ្សាយកម្មវិធី "ពន្លឺភ្លើងទៀន" របស់គណបក្សសមរង្ស៊ី ដែលជារឿយៗបានប្រើប្រាស់ពាក្យជេប្រមាថដល់ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា ជាពិសេស

---

[២] វិទ្យុផ្សាយបន្តផ្ទាល់រួមមាន: វិទ្យុ FM 88 MHz វិទ្យុ FM 97 MHz វិទ្យុ FM 98 MHz វិទ្យុ FM 99 MHz វិទ្យុ FM 103 MHz និងវិទ្យុផ្សាយបន្តរបស់វិទ្យុទាំងនេះ។ វិទ្យុទាំងនេះមិនបានប្រកាសជួលម៉ោងដល់គណបក្សនយោបាយទេ។

[៣] តាមសេចក្តីប្រកាសគជប ប្រ.ក/លេខ ០៦.០៩៦.០៨ គ.ជ.ប/អគ.ពស ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៨: ប្រព័ន្ធផ្សព្វផ្សាយជួលម៉ោងផ្សាយដល់គណបក្សនយោបាយរួមមាន: វិទ្យុ FM 105 MHz វិទ្យុ FM 104 MHz និងវិទ្យុ FM 93.5 MHz។

ដូចជា ពាក្យ "ពួកចោរលួចជាតិ/លក់ជាតិ" ជាដើម។

វិទ្យុតាព្រហ្ម FM 90.5MHz ដែលមាននិន្នាការគាំទ្រគណបក្សហ៊្វុនស៊ិនប៉ិច បាន និងកំពុងតែផលិតកម្មវិធី និងផ្សព្វផ្សាយបំរើឱ្យគណបក្ស ហ៊្វុនស៊ិនប៉ិច តែប៉ុណ្ណោះ ដែលមិនបានប្រកាសជួលម៉ោងឱ្យគណបក្សផ្សេងៗនោះទេ។

**៤.២ ការវិភាគសម្លេងខ្លឹមសារទៅលើប្រព័ន្ធផ្សព្វផ្សាយដែលខុមហ្វ្រែលអង្កេតពិស្តា**

ប្រព័ន្ធផ្សព្វផ្សាយ[៤]ដែលខុមហ្វ្រែលអង្កេតពិស្តារួមមានៈ ទូរទស្សន៍ជាតិកម្ពុជា (ទទក) បណ្តាញទូរទស្សន៍កម្ពុជា (ស៊ីធីអិន) វិទ្យុជាតិកម្ពុជា FM 96 MHz និង AM 918 KHz វិទ្យុសំបុកឃ្មុំ FM 105 MHz វិទ្យុ FM 102 MHz វិទ្យុអាស៊ីសេរី (RFA) វិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA) និងវិទ្យុបារាំងអន្តរជាតិ (RFI) ដោយអង្កេតការផ្សាយពីម៉ោង ១៧:០០ ដល់ ២៣:០០។

ដោយសរុបលទ្ធផលនៃការអង្កេតប្រព័ន្ធផ្សព្វផ្សាយទាំងនេះ (ពីថ្ងៃទី ២៦ មិថុនា ដល់ ១០ កក្កដា ឆ្នាំ ២០០៨) គណបក្សសមរង្ស៊ី និងគណបក្សប្រជាជនកម្ពុជាត្រូវបានប្រព័ន្ធផ្សព្វផ្សាយប្រមាណ ១២% (ប្រមាណជា ១១ ម៉ោង ៣៥ នាទី) នៃការផ្សាយពីគណបក្សនយោបាយទាំងអស់។ ក្នុងប្រព័ន្ធផ្សព្វផ្សាយដែលអង្កេត មានតែទូរទស្សន៍ស៊ីធីអិនតែមួយគត់ ដែលផលិត និងផ្សព្វផ្សាយលម្អៀងគាំទ្រយ៉ាងខ្លាំងដល់គណបក្សប្រជាជនកម្ពុជា។ ចំណែកគណបក្សនរោត្តមរណឫទ្ធិ គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសិទ្ធិមនុស្ស ត្រូវបានផ្សព្វផ្សាយប្រមាណ ១០% (ប្រមាណជា ៩ ម៉ោង)។ គណបក្សខ្មែរសាធារណរដ្ឋ ត្រូវបានផ្សព្វផ្សាយតិចជាងគេ ដែលមានចំនួនប្រមាណ ៥% (ស្មើនឹង ៤ ម៉ោង ២៩ នាទី) ចំណែកគណបក្សនយោបាយផ្សេងៗទៀតត្រូវបានផ្សព្វផ្សាយចន្លោះពី ៧% (ប្រមាណ ៦ ម៉ោង ៣០ នាទី) ទៅ ៩% (ប្រមាណ ៨ ម៉ោង ៣៥ នាទី)។

មានការផ្សាយអវិជ្ជមានចំពោះគណបក្សប្រជាជនកម្ពុជា ដូចជាវិទ្យុអន្តរជាតិអាស៊ីសេរី បានធ្វើបទសម្ភាសន៍ជាមួយនាយកប្រតិបត្តិអង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំអាស៊ី (Human Right Watch) ដោយបានរំឭកដល់អំពើហឹង្សា ដែលជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលសម្តេច ហ៊ុន សែន រួមមានអំពើឃាតកម្ម ទារុណកម្ម ទៅលើមន្ត្រីរបស់គណបក្សហ៊្វុនស៊ិនប៉ិចនៅក្នុងអំឡុងពេលរដ្ឋប្រហារថ្ងៃទី ៥-៦ ខែ កក្កដា ឆ្នាំ ១៩៩៧។ វិទ្យុនេះបានស្នើសុំការបំភ្លឺ ពីនាយករដ្ឋមន្ត្រី និងអគ្គស្នងការនគរបាលជាតិផងដែរ តែមិនទាន់មានការឆ្លើយតបនៅឡើយទេ។

កម្មវិធីស្មើភាពរបស់ គ.ជ.ប នៅក្នុងប្រព័ន្ធផ្សព្វផ្សាយរដ្ឋ បានផ្តល់ពេលវេលាស្មើគ្នា (រយៈពេល ១០ នាទី ក្នុងមួយដងក្នុងមួយថ្ងៃ-មួយថ្ងៃផ្សាយពីរដង) ទៅឱ្យគណបក្សនយោបាយនិមួយៗ។ ទោះបីយ៉ាងណា ការសង្កេតឃើញថា រាជ-រដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជាផ្ទាល់ បានទទួលរងការរិះគន់ ដោយម៉ោងសរុបភាគច្រើននៃគណបក្សនយោបាយ

---

[៤] ប្រព័ន្ធផ្សព្វផ្សាយទាំងនេះ ត្រូវបានជ្រើសរើសដោយផ្អែកទៅលើជារបស់សាធារណៈ ឯករាជភាព ឬ ប្រជាប្រិយភាព។ ខុមហ្វ្រែលសន្មតថាប្រព័ន្ធផ្សព្វផ្សាយឬកម្មវិធីមួយចំនួនធំដែលមាននិន្នាការគាំទ្រគណបក្សនយោបាយនោះទាំងស្រុងគឺលម្អៀងទៅកាន់គណបក្ស គណបក្សនយោបាយណាមួយដែលគេប្រកាន់យក។ ដូចនេះ ខុមហ្វ្រែលមិនអង្កេតរយៈផ្សាយ ខ្លឹមសាររបស់ប្រព័ន្ធផ្សព្វផ្សាយលម្អៀងទាំងនោះទេ ប៉ុន្តែពិនិត្យអំពីកម្រិតនៃការគោរពក្រមសីលធម៌ និងគោលការណ៍ណែនាំរបស់ គជប។

១០ ផ្សេងទៀត។ ការទិតៀន រួមមាន ទំនិញឡើងថ្លៃ បញ្ហាដីធ្លី ការបំផ្លាញធនធានធម្មជាតិ ជាពិសេស ព្រៃឈើ ជន-អន្តោប្រវេសន៍ អំពើពុករលួយ អំណាចផ្តាច់ការ និងភាពអយុត្តិធម៌ក្នុងសង្គម។

នៅក្នុងពេលឃោសនានេះ សកម្មភាពឃោសនាមានឥទ្ធិពលគួរឱ្យចាប់អារម្មណ៍មួយចំនួនដូចជា គណបក្សប្រជាជនកម្ពុជា **បានយកលទ្ធផលនៃការចុះបញ្ជីប្រាសាទព្រះវិហារជាបេតិកភ័ណ្ឌពិភពលោក យកមកធ្វើការឃោសនាបន្ថែមទៅ**នឹងសមិទ្ធផលជាច្រើនដែលគណបក្សនេះបានលើកឡើងនាពេលកន្លងមក។ ប្រការនេះ ត្រូវបានគេចោទប្រកាន់ថា ជាការកេងចំណេញខាងនយោបាយហើយថាលទ្ធផលនេះ គឺកើតចេញមកពីការខិតខំរបស់ប្រជាពលរដ្ឋកម្ពុជាទាំងមូល។ ចំណែក**មេដឹកនាំគណបក្សសមរង្ស៊ី បានលើកយករបាយការណ៍ស្តីពីការកាប់បំផ្លាញព្រៃឈើ របស់អង្គការគ្លូបលវីតនេស** (Global Witness) មកលាតត្រដាង និងបានប្រើពាក្យចោទប្រកាន់មេដឹកនាំរាជរដ្ឋាភិបាលបច្ចុប្បន្ន ថាជា "ចោរលួចជាតិ" ដែលករណីនេះបានធ្វើឱ្យតំណាងគណបក្សប្រជាជនកម្ពុជា បានដាក់ពាក្យប្តឹងជាបន្តបន្ទាប់នៅតាមខេត្ត/ក្រុងដែលមេដឹកនាំគណបក្សសមរង្ស៊ីបាន ធ្វើសកម្មភាពឃោសនាបោះឆ្នោត។

**៥- តួនាទីអ្នកសង្កេតការណ៍ក្នុងការជួយអ្នកបោះឆ្នោតមិនត្រូវបានលើកទឹកចិត្ត**

ខុមហ្វ្រែល មានការសោកស្តាយដែល **គ.ជ.ប មិនផ្តល់សិទ្ធិ និងតួនាទីអ្នកសង្កេតការណ៍ក្នុងការជួយអ្នកបោះ-ឆ្នោត** ដោយលើកហេតុផលថា បង្កឱ្យបាត់សណ្តាប់ធ្នាប់ របៀបរៀបរយនៅក្នុង(ក្រៅបន្ទប់)ការិយាល័យបោះឆ្នោត និងជ្រៀតជ្រែកដល់ដំណើរការរៀបចំការបោះឆ្នោតទៅវិញ[៥]។ ក្នុងថ្ងៃបោះឆ្នោតនាពេលកន្លងៗមកនេះ មានអ្នកបោះឆ្នោតជាច្រើនមានការលំបាកក្នុងការរកឈ្មោះ ឬរកឈ្មោះមិនឃើញ ឬត្រូវបានបដិសេធសិទ្ធិបោះឆ្នោត។ ម្យ៉ាងទៀត ការលុបឈ្មោះអ្នកបោះឆ្នោតមានខុសនីតិវិធីច្រើន និងអ្នកបោះឆ្នោតមួយចំនួន មិនបានទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ដូចនេះហើយ ខុមហ្វ្រែល មានបំណងចង់ឱ្យអ្នកសង្កេតការណ៍ខ្លួន ជួយអ្នកបោះឆ្នោតដែលជំនួយការទីពីរ នៃមន្ត្រីការិយាល័យបោះឆ្នោតពុំមានលទ្ធភាព ជួយអ្នកបោះឆ្នោតរកការិយាល័យ និងឈ្មោះមិនឃើញ។ ក្នុងសកម្មភាពជួយនោះ អ្នកសង្កេត-ការណ៍ ក៏ត្រូវគោរពក្រមសីលធម៌ដែរ។ ដោយសារតែក្រមសីលធម៌ខុសគ្នា ខុមហ្វ្រែល យល់ថា សិទ្ធិ និងតួនាទីអ្នកសង្កេតការណ៍ របស់អង្គការមិនមែនរដ្ឋាភិបាល ដែលមិនដូចជាភ្នាក់ងារគណបក្សនយោបាយ ឬមេភូមិ និងអាជ្ញាធរមូលដ្ឋាននោះទេ។

*សម្រាប់ព័ត៌មានផ្សេងៗសូមទាក់ទង:*

- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៩៤២ ០១៧
- លោក **ម៉ារ សុផល** ប្រធានផ្នែកអង្កេត ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៥ ០៩១

*បេសកកម្មទី ១ របស់ ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តធម៌ តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតអំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយ ដែលមិនលំអៀង និងមិនប្រកាន់បក្សពួក។*

---

[៥] យោងលិខិតឆ្លើយតបរបស់ គ.ជ.ប លេខ ៧២៤/០៨ ចុះថ្ងៃទី ០៩ កក្កដា ២០០៨។